**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

លេខ : ៤៧៣ មស.ភដ៣

## សេចក្តីជូនដំណឹង
## ស្តីពី
## ការដំឡើងថ្នាក់ ឋានន្តរស័ក្តិជូនមន្ត្រីរាជការស៊ីវិលសម្រាប់ឆ្នាំ២០១៦

អនុលោមព្រះរាជក្រមលេខ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

ក្រសួងមុខងារសាធារណៈ មានកិត្តិយសសូមគោរពជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន ឯកឧត្តមអភិបាលនៃគណៈអភិបាល រាជធានី ខេត្ត និង លោក លោកស្រីប្រធានមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត មេត្តាជ្រាបថា ក្នុងគោលបំណងរក្សាផលប្រយោជន៍ជូនមន្ត្រីរាជការស៊ីវិលរបស់យើង អនុលោមខ្លឹមសារច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក្រសួងមុខងារសាធារណៈ សូមដាក់ចេញនូវសេចក្តីជូនដំណឹងសម្រាប់អនុវត្តនិងសហការអនុវត្តដូចខាងក្រោម៖

- ការដំឡើងថ្នាក់ ឋានន្តរស័ក្តិជូនមន្ត្រីរាជការស៊ីវិល ត្រូវអនុវត្តអនុលោមមាត្រា២០និងមាត្រាបន្តបន្ទាប់នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ព្រមទាំងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ការគិតគូរដំឡើងថ្នាក់ ឋានន្តរស័ក្តិជូនមន្ត្រីរាជការស៊ីវិលក្នុងឆ្នាំ២០១៦នេះ ត្រូវគិតចំពោះមន្ត្រីរាជការស៊ីវិលដែលខិតខំបម្រើការងារពិតប្រាកដនិងមានរយៈពេលអប្បបរិមានៃការឡើងថ្នាក់ត្រូវកម្រិត២(ពីរ)ឆ្នាំ គិតមកដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៦
- ការគិតគូរដំឡើងថ្នាក់ជូនមន្ត្រីរាជការស៊ីវិលក្នុងឆ្នាំ២០១៦នេះ ត្រូវគិតចំពោះមន្ត្រីរាជការស៊ីវិលដែលបានធ្វើនិយ័តកម្មថ្នាក់ ឋានន្តរស័ក្តិឬធ្វើសមាហរណកម្មរួចរាល់ហើយ តែនៅសល់អតីតភាពការងារ
- ចំពោះមន្ត្រីរាជការស៊ីវិលដែលត្រូវស្នើសុំដំឡើងថ្នាក់ ឋានន្តរស័ក្តិដោយសំអាងលើសញ្ញាបត្រពិតប្រាកដនោះ ត្រូវអនុវត្តអនុលោមលិខិតបទដ្ឋានគតិយុត្តជាធរមាននិងអនុលោមពេលវេលាដែលបានកំណត់ក្នុងលិខិតលេខ០៥៣ មស.នក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៩ ស្តីពីការណែនាំបន្ថែមនូវនីតិវិធីក្នុងការដំឡើងថ្នាក់ ការតាំងស៊ប់មន្ត្រីរាជការក្របខណ្ឌថ្មី និងការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍តាមគោលការណ៍។

ក្រសួងមុខងារសាធារណៈ សង្ឃឹមថា សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងលោក លោកស្រីប្រធានមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ តាមការគួរ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ មីនា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ពេជ្រ ប៊ុនធិន**

**ចម្លងជូន៖**

- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- មន្ទីរនិងអង្គភាពជំនាញរាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh